**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០១ ក.យ.សណន/១៥

# សេចក្តីណែនាំ
## ស្តីពី
## និរន្តរភាព ប្រសិទ្ធភាព និងសុខដុមនីយកម្ម នៃអង្គភាពរដ្ឋបាលនៃសាលាដម្រះក្តី

អនុលោមតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ក្រសួងយុត្តិធម៌បានរៀបចំបទដ្ឋានគតិយុត្តិក្រោមច្បាប់មួយចំនួន ដើម្បីគាំទ្រដល់កិច្ចដំណើរការរបស់អង្គការតុលាការ និងអង្គការអយ្យការ ជាពិសេសអនុក្រឹត្យពាក់ព័ន្ធនឹងការរៀបចំអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី។

ដោយហេតុថាការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុរបស់សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី ជាការងារចាំបាច់ដែលត្រូវធានានិរន្តរភាព និងប្រសិទ្ធភាព ក្រសួងយុត្តិធម៌បានរៀបចំសំណើតែងតាំងប្រធានអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី ក៏បានធ្វើការណែនាំឲ្យប្រធានអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តីចូលកាន់តំណែងរួចរាល់។ ប៉ុន្តែកន្លងមកក្រសួងពិនិត្យឃើញថា អង្គភាពរដ្ឋបាលនៃសាលាជម្រះក្តីនៅពុំទាន់អាចរៀបចំ និងដំណើរការបានល្អនៅឡើយ ដែលធ្វើឲ្យមានការរាំងស្ទះដល់ប្រសិទ្ធភាពនៃការរៀបចំប្រព័ន្ធរដ្ឋបាលរបស់សាលាជម្រះក្តី ស្របតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។

អាស្រ័យហេតុនេះ ដើម្បីធានាប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និរន្តរភាព និងសុខដុមនីយកម្មនៃអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

១. រចនាសម្ព័ន្ធរបស់អង្គការតុលាការ និងអង្គការអយ្យការ ត្រូវរៀបចំឲ្យបានស្របតាមស្មារតីនៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឲ្យបានឆាប់រហ័ស។

២. ចាប់ពីមានការតែងតាំងប្រធានអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី ស្របតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ តំណែងនាយកក្រឡាបញ្ជីតុលាការ និងនាយកក្រឡាបញ្ជីអយ្យការ ពុំមានអត្ថិភាពទៀតទេ។

៣. គ្រប់នាយកក្រឡាបញ្ជី និង/ឬក្រឡាបញ្ជី ត្រូវផ្ទេរការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុរបស់សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី ដែលខ្លួនធ្លាប់ទទួលបន្ទុកពីមុន មកឲ្យប្រធានអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី ដើម្បីអនុវត្តឲ្យបានស្របតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។

៤. ក្រឡាបញ្ជីដែលត្រូវបានតែងតាំង នៅក្នុងរចនាសម្ព័ន្ធរបស់អង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី នៅបន្តលក្ខន្តិកៈជាក្រឡាបញ្ជី ប៉ុន្តែមិនអាចបំពេញមុខងារក្រឡាបញ្ជី ដែលជាជំនួយដល់ចៅក្រម និងព្រះរាជអាជ្ញា ក្នុងនីតិវិធីតុលាការ និងអយ្យការ (កាន់សំណុំរឿង) ឡើយ។

៥. ករណីអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី ពុំមានមន្ត្រីគ្រប់គ្រាន់សម្រាប់ដំណើរការ ប្រធានសាលាជម្រះក្តីអាចស្នើសុំមកក្រសួង ដើម្បីចាត់តាំងក្រឡាបញ្ជីឲ្យជួយការងាររដ្ឋបាលជាបណ្តោះអាសន្នបាន។

៦. មន្ត្រីរដ្ឋបាល ក្រឡាបញ្ជី អាជ្ញាសាលា មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតទាំងអស់ ដែលបម្រើការងារនៅសាលាជម្រះក្តី ត្រូវដាក់ឲ្យស្ថិតក្រោមការសម្របសម្រួល និងគ្រប់គ្រងរបស់អង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី។

៧. ចៅក្រម និងព្រះរាជអាជ្ញារង មិនអាចចាត់ចែងការងាររបស់អង្គភាពរដ្ឋបាលនៃសាលា-ជម្រះក្តីឡើយ។

៨. ប្រធានសាលាជម្រះក្តី ប្រធានអង្គការអយ្យការអមសាលាជម្រះក្តី និងប្រធានអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី ត្រូវបង្កើនកិច្ចសហការ និងសម្របសម្រួល ដើម្បីរៀបចំឲ្យអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តីមានកិច្ចដំណើរការល្អ ហើយក្នុងករណីចាំបាច់ត្រូវរាយការណ៍មកក្រសួងយុត្តិធម៌។

ទទួលបានសេចក្តីណែនាំនេះ ប្រធានសាលាជម្រះក្តី ប្រធានអង្គការអយ្យការអមសាលាជម្រះក្តី ប្រធានអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី និងអង្គភាពពាក់ព័ន្ធ ត្រូវចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាព ដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃទីចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

អង្គ វង្ស វឌ្ឍនា

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- អង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- អង្គភាពរដ្ឋបាលនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- គ្រប់ក្រសួង-ស្ថាប័ន
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ